ធ៧-០១-១៣៧ ប្រ.ក

# ប្រកាស
# ស្តីពី
# ឥណទានចំពោះសម្ព័ន្ធញាតិ

ធ្វើវិសោធនកម្មដោយ ប្រកាស ធ៧-០២-១៤៦ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០២ ស្តីពី វិសោធនកម្មលើប្រកាសលេខធ៧-០១-១៣៧ ប្រក ស្តីពី ឥណទានចំពោះសម្ព័ន្ធញាតិ។

**ប្រការ ១**.-

សម្ព័ន្ធញាតិដូចមានចែងនៅមាត្រាទី៤៩ និង៥០ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមបញ្ញត្តិនៃប្រកាសនេះ។

**ប្រការ ២**.-

ឥណទាននិងឥណទានលើសសមតុល្យចំពោះសម្ព័ន្ធញាតិត្រូវអនុវត្តតាមលក្ខខណ្ឌធម្មតានៃថេរៈវេលា អត្រាការប្រាក់វត្ថុបញ្ចាំនិងកាលវិភាគត្រូវទូទាត់សងវិញ។

លក្ខខណ្ឌធម្មតាក្នុងន័យនេះ គឺជាលក្ខខណ្ឌដែលត្រូវអនុវត្តចំពោះអតិថិជនមិនមែនសម្ព័ន្ធញាតិ ក្នុងកាលៈទេសៈដូចគ្នា។

**ប្រការ ៣**.-

បញ្ញត្តិដែលមានចែងក្នុងមាត្រា ២ មិនអនុវត្តចំពោះបំណុលបំពេញលើដើមទុន ( Subordinated debts) ដែលផ្តល់ដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា និងកាន់កាប់ដោយគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុកម្ពុជា ដែលជាក្រុមហ៊ុនមេរបស់ពួកគេឡើយ។

**ប្រការ ៤**.-

(ធ្វើវិសោធនកម្មដោយ ប្រកាស ធ៧-០២-១៤៦ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០២)

សរុបឥណទានដក់សល់ថ្លឹងចំពោះសម្ព័ន្ធញាតិ មិនត្រូវឱ្យលើសពី១០%នៃមូលនិធិផ្ទាល់សុទ្ធទេ ទោះជាក្នុងករណីណាក៏ដោយ។ ការគណនាឥណទានសម្ព័ន្ធញាតិមិនត្រូវរួមបញ្ចូលការតំកល់ប្រាក់នៅទីស្នាក់ការកណ្តាល ឬនៅក្រុមហ៊ុនមេ ក្រោមលក្ខខណ្ឌពីរដូចខាងក្រោមៈ

- ទីស្នាក់ការកណ្តាល ឬក្រុមហ៊ុនមេជាធនាគារ
- ត្រូវមានភស្តុតាងបង្ហាញថាធនាគារមានចំណាត់ថ្នាក់ស្មើ ឬខ្ពស់ជាង A- តាមវិធីសាស្រ្ត Standard & Poor ឬតាមវិធីសាស្រ្តសមមូលដោយភ្នាក់ងារចាត់ថ្នាក់ដែលអន្តរជាតិទទួលស្គាល់។

ឥណទានដក់សល់ត្រូវគណនាទៅតាមប្រកាសស្តីពីអនុបាតសាធនភាព (ប្រកាសបច្ចុប្បន្ន លេខ ធ៧-០០-៤៦ ប្រ.ក)។

មូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ ត្រូវគណនាស្របតាមប្រកាសស្តីពីការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ (ប្រកាសបច្ចុប្បន្ន លេខ ធ៧-០១០-១៨២ ប្រ.ក )។

**ប្រការ ៥**.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនីមួយៗ ត្រូវធ្វើប្រតិវេទន៍ប្រចាំត្រីមាសលើឥណទានដែលពាក់ព័ន្ធជូនធនាគារជាតិនៃកម្ពុជាស្របតាមគំរូដែលមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

អត្ថបទចម្លងនៃប្រតិវេទន៍នេះ ត្រូវចម្លងជូនក្រុមប្រឹក្សាភិបាលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ៦**.-

ការខកខានមិនបានអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ត្រូវទទួលរងទណ្ឌកម្មដែលមានចែងត្រង់មាត្រា ៥២ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ៧**.-

រាល់លិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៨**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាពគ្រប់គ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៩**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**